**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ការផ្អាកការសិក្សាជាបណ្តោះអាសន្ន នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ពីថ្នាក់មត្តេយ្យសិក្សា ដល់ថ្នាក់ឧត្តមសិក្សា នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប**

ក្រសួងអប់រំ យុវជន និងកីឡា សូមជម្រាបជូនដល់ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្ស និងសាធារណជនទាំងអស់មេត្តាជ្រាបថា៖ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ទាំងអស់នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប ត្រូវបិទទ្វារផ្អាកការសិក្សាជាបណ្តោះអាសន្នចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រហូតដល់មានការជូនដំណឹងជាថ្មី។ វិធានការនេះជាការចូលរួមទប់ស្កាត់ការរីករាលដាល នៃជំងឺ Covid-19 បន្ទាប់ពីមានការរកឃើញករណីមេរោគនេះ នៅលើបុរសជនជាតិខ្មែរម្នាក់ ដែលប៉ះពាល់ផ្ទាល់ជាមួយជនជាតិជប៉ុនមានផ្ទុកមេរោគ Covid-19 ហើយបានចាកចេញពីខេត្តសៀមរាប ទៅកាន់ប្រទេសជប៉ុន កាលពីពេលថ្មីៗ នេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្ស និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការដោយស្មារតីយោគយល់ អនុវត្តឱ្យខ្ជាប់ខ្ជួននូវវិធានការបង្ការទប់ស្កាត់របស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានដាក់ចេញ ដោយការទទួលខុសត្រូវខ្ពស់បំផុត និងតាមដានការផ្សព្វផ្សាយទាំងឡាយរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល។

ថ្ងៃសៅរ៍ ១៤កើត ខែផល្គុន ឆ្នាំជូត ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០

ក្រសួងអប់រំ យុវជន និងកីឡា